ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

បានចំលងចេញត្រឹមត្រូវតាមច្បាប់ដើម
ខេត្តកណ្ដាល ថ្ងៃទី ២៨ ខែ ០៣ ឆ្នាំ២០២៣
ក្រឡាបញ្ជី
ឡុង ឡុក

**សាលាដំបូងខេត្តកណ្ដាល**

សំណុំរឿងព្រហ្មទណ្ឌលេខៈ ១៣៩៤ អក
ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២២
សាលក្រមលេខៈ ២៣ "ត"
ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣

## តាមនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកណ្ដាល

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២៣
ដោយមានសមាសភាពដូចតទៅ:

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោកស្រី [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
លោក [redacted] ចៅក្រមប្រឹក្សា
លោកស្រី [redacted] ចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកណ្ដាល

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តកណ្ដាល

ដើម្បីជំនុំជម្រះ សំណុំរឿងព្រហ្មទណ្ឌលេខៈ ១៣៩៤ អ.ក ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២២ ៖

ជនជាប់ចោទឈ្មោះ [redacted] សំណាង ភេទប្រុស អាយុ១៥ឆ្នាំ (កើតឆ្នាំ២០០៧) អនីតិជន ជាតិខ្មែរ មុខរបរសិស្ស កម្រិតវប្បធម៌ថ្នាក់ទី៩ មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្តកណ្ដាល ឪពុកឈ្មោ [redacted] សារ៉ែន (រស់) ម្ដាយឈ្មោះ [redacted] ឿន (រស់) នៅលីវ ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការគ្មាន ។ (ឃុំខ្លួន នៅថ្ងៃទី១៩.០៩.២០២២)

ជននេះត្រូវបានដាក់ឲ្យស្ថិតក្រោមការពិនិត្យពីបទៈ រួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ ប្រព្រឹត្តនៅភូមិព្រែកថោង ឃុំព្រែកលួង ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល កាលពីថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២២។ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤២ នៃច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចន្ថា ភេទស្រី អាយុ៣៦ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ មានទីលំនៅបច្ចុប្បន្ននៅភូមិព្រែកថោង ឃុំព្រែកលួង ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល។

មេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សំណាង ។

មេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនរងគ្រោះឈ្មោះ [redacted] រីតា ។

Scanned with CamScanner

- បានឃើញពាក្យបណ្ដឹង ចុះថ្ងៃទី១៨-០៩-២០២២។
- បានឃើញរបាយការណ៍លេខ ៤២០ របក ចុះថ្ងៃទី១៩-០៩-២០២២ របស់អធិការដ្ឋាននគរបាលស្រុកខ្សាច់កណ្ដាល។
- បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ១១០១ដកសស ចុះថ្ងៃទី១៩-០៩-២០២២។
- បានឃើញដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ៣៥៣០ ដកបឃខ ចុះថ្ងៃទី១៩-០៩-២០២២។
- បានឃើញពាក្យសុំការពារក្ដីលេខ ០៣/២២ ក.ម.ល.ថ/AN ចុះថ្ងៃទី២១-០៩-២០២២។
- បានឃើញលិខិតលេខ ០៣៩/ប្រ.គម/កណ ចុះថ្ងៃទី២៨-០៩-២០២២ ស្ដីពីការចាត់តាំងមេធាវី។
- បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ១១៨២ ដក.សព ចុះថ្ងៃទី១១-១០-២០២២។
- បានឃើញដីកាដំណោះស្រាយលេខ ១២១៨ ដក.ដស ចុះថ្ងៃទី១៩-១០-២០២២។
- បានឃើញដីកាបង្គាប់ឲ្យរក្សាទុកជនជាប់ចោទនៅក្នុងឃុំបណ្ដោះអាសន្នលេខ ២២៤៦ ដករជបឃ ចុះថ្ងៃទី១៩-១០-២០២២។
- បានឃើញដីកាចាត់តាំងប្រធានក្រុមប្រឹក្សាជំនុំជម្រះលេខ ១២៥០ ដក.ចត ចុះថ្ងៃទី២០-១០-២០២២ របស់ប្រធានសាលាដំបូងខេត្តកណ្ដាល ។
- បានឃើញពាក្យការពារក្ដីលេខ ២៧១/CDS ចុះថ្ងៃទី១៤-១១-២០២២។

## នាពេលសវនាការ

- តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សំណាង នាពេលសវនាការថា: ខ្លួនរក្សាចម្លើយពីមុនដដែល។ នៅថ្ងៃទី១៦.០៩.២០២២ ខ្លួននៅផ្ទះខ្លួនលក់ឥវ៉ាន់ចាប់ហួយជាមួយប្អូនខ្លួនឈ្មោះ [redacted] ស្រីនីត ពេលញ៉ាំបាយថ្ងៃត្រង់រួច ខ្លួនបានឲ្យប្អូនស្រីខ្លួនឈ្មោះ [redacted] ស្រីនីត ទៅហៅ នីតា មកផ្ទះខ្លួន ពេល នីតា មកដល់ផ្ទះខ្លួនដំបូង នីតា អង្គុយលេងធម្មតា រួចខ្លួនចាប់ផ្ដើមនិយាយលួងលោមបបួល នីតា ឡើងលើផ្ទះ ដំបូង នីតា អត់ហ៊ានឡើងទេ ដោយខ្លាចឆ្កែនៅលើកាំជណ្ដើរ រួចខ្លួនឡើងទៅចាប់ឆ្កែ ទើបនីតាឡើងលើផ្ទះ ខ្លួនចុះមកលក់ឥវ៉ាន់ឲ្យគេរួច ទើបឡើងលើផ្ទះវិញ ឯប្អូនខ្លួននៅលេងខាងក្រៅផ្ទះ ខ្លួនក៏ធ្វើសកម្មភាពទ្រាបពីលើ នីតា ដោយខ្លួនស្រាតខោខ្លួនចេញ និងខ្លួនបានស្រាតខោនីតា រួចហើយ រួចខ្លួនយកប្រដាប់ភេទខ្លួនដាក់ចូលប្រដាប់ភេទនីតាម្ដង ញ៉ុលៗពីលើអត់ចូលខាងក្នុងទេ ញ៉ុលៗ២, ៣ដង ទើបខ្លួនចេញទឹកកាម រួចខ្លួនឲ្យនីតាស្លៀកខោរួចចុះទៅក្រោមវិញ។ នីតា អត់យំទេ។ នីតា អត់ប្រាប់ថា ឈឺទេ។ កន្លងមកខ្លួនអត់ធ្លាប់ធ្វើអញ្ចឹងទេ។ ខ្លួនស្គាល់ឈ្មោះ នីតា ដោយសារនៅផ្ទះជិតគ្នា។ ខ្លួនរៀនថ្នាក់ទី៩។ ខ្លួនទើបធ្វើដាក់ឈ្មោះ នីតា ម្ដងទេ។ ខ្លួនបាននិយាយជាមួយឈ្មោះ នីតា ថាកុំឲ្យប្រាប់អ្នកណាគេ តែខ្លួនអត់បាននិយាយថាកុំឲ្យប្រាប់ម៉ាក់ទេ។ ខ្លួនមានការសោកស្ដាយ ខ្លួនឈប់ធ្វើអញ្ចឹងទៀតហើយ។ ខ្លួនរៀនថ្នាក់ទី៩ នៅវិទ្យាល័យព្រែកលួង។

- តាមចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចន្ទា នាពេលសវនាការថា: ខ្លួនត្រូវជា

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ខេត្តកណ្ដាល ថ្ងៃទី ២៨ ខែ [illegible] ឆ្នាំ ២០២៣
ក្រឡាបញ្ជី
[redacted]

ម្ដាយបង្កើតរបស់ឈ្មោះ [redacted] នីតា។ កូនខ្លួនរាល់ដងនៅលេងផ្ទះជួល អត់ដែលទៅលេងផ្ទះរបស់ឈ្មោះ សំណាងទេ។ ថ្ងៃកើតហេតុថ្ងៃទី១៦ ចំថ្ងៃដាក់បិណ្ឌ។ ពេលដឹងភ្លាមខ្លួនទៅប្រាប់ម្ដាយរបស់ឈ្មោះ សំណាង រួចម្ដាយសំណាង បាននាំកូនខ្លួនទៅពេទ្យ ពេលពិនិត្យរួច ពេទ្យប្រាប់ថាអត់មានបញ្ហាអ្វីទេ។ ពេទ្យឲ្យឯកសារដែរ តែបាត់ហើយ។ ថ្ងៃសុក្រ ក្រោយពេលកូនខ្លួនទៅផ្ទះឈ្មោះ សំណាង បាន២ថ្ងៃ កូនខ្លួនប្រាប់ថា កូនឈឺក្ដិតដូចមានអីចាក់ក្ដិតកូន ខ្លួនបានស្រាតខោកូនមើល ឃើញមានទឹកសើមៗហូរប្លែក ខ្លួនក៏មុជទឹកឲ្យកូន ពេលមុជទឹករួច ខ្លួនសួរកូនៗអត់បានប្រាប់ទេ ដល់ពេលចូលគេងខ្លួនសួរម្ដងទៀត ថាមានអ្នកណាលេងក្ដិតកូនអត់ ទើបកូនប្រាប់ថា បងណាង។ អាការៈកូនខ្លួនសព្វថ្ងៃជាហើយ។ ខ្លួនទាមទារសំណងជំងឺចិត្តជាប្រាក់ចំនួន ១០០០០ (មួយម៉ឺន) ដុល្លាអាមេរិក។

- តាមចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចន្ថា នៅចៅក្រមស៊ើបសួរថា: ចំពោះរឿងហេតុដែលបានកើតឡើងគឺ នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២២ វេលាម៉ោង១១ និង៣០នាទីថ្ងៃ ពេលនោះប្អូនបង្កើតរបស់ជនល្មើសឈ្មោះ [redacted] សំណាង បានមកបបួលកូនស្រីរបស់ខ្លួនឈ្មោះ [redacted] នីតា ភេទស្រី អាយុ៦ឆ្នាំ ទៅលេងបាយឡុងបាយឡនៅផ្ទះរបស់ឈ្មោះ [redacted] សំណាង។ នៅពេលនោះខ្លួនមិនបានទៅតាមកូនទេ ដោយជាប់រវល់ចងបន្លែ ដើម្បីទុកលក់។ បន្ទាប់មកនៅវេលាម៉ោងប្រហែល ៣រសៀល ពេលនោះកូនស្រីរបស់ខ្លួនឈ្មោះ [redacted] នីតា បានត្រឡប់មកពីផ្ទះរបស់ឈ្មោះ [redacted] សំណាង នៅពេលនោះកូនស្រីរបស់ខ្លួនឈ្មោះ [redacted] នីតា មិនបានប្រាប់ខ្លួនពីសកម្មភាពដែលជនល្មើសឈ្មោះ [redacted] សំណាង ធ្វើសកម្មភាពមកលើកូនស្រីខ្លួននោះទេ។ បន្ទាប់មកនៅថ្ងៃសុក្រ ទី១៧ ខែកញ្ញា ឆ្នា២០២២ វេលាម៉ោង០៩យប់ ទើបកូនស្រីខ្លួនឈ្មោះ [redacted] នីតា បានប្រាប់ខ្លួនថា ម៉ាក់កូនឈឺក្ដិតណាស់ ពេលនោះខ្លួនក៏បានសួរទៅកូនស្រីខ្លួនបន្តទៀតថា មាននរណាធ្វើអ្វីកូនឬអត់ ប៉ុន្តែពេលនោះកូនស្រីខ្លួនមិនទាន់បានប្រាប់ខ្លួនទេ ហើយខ្លួនក៏បានយកកូនស្រីទៅមុជទឹក បន្ទាប់មកខ្លួនក៏បានសួរបន្តទៀតថា នរណាធ្វើអីកូន ទើបកូនស្រីខ្លួនបាននិយាយប្រាប់ខ្លួនថា បងណាង កូនយាយយឿន បាននិយាយថាបបួលខ្ញុំចុយគ្នា ហើយបន្ទាប់មកខ្លួនក៏នាំកូនស្រីទៅចូលគេងទៅ។ បន្ទាប់ពីបានសួរកូនស្រីខ្លួនឈ្មោះ [redacted] នីតា រួចមកខ្លួនក៏បានទៅប្រាប់ម្ដាយរបស់ជនល្មើសឈ្មោះ [redacted] យឿន ថាកូនមីងបានលេងក្ដិតកូនស្រីរបស់ខ្លួន។ លុះព្រឹកឡើងម្ដាយរបស់ជនល្មើសឈ្មោះ [redacted] យឿននេះក៏បាននាំកូនស្រីខ្លួនទៅមន្ទីរពេទ្យ ដើម្បីឲ្យគ្រូពេទ្យពិនិត្យតែម្ដង ហើយចំពោះលទ្ធផលពិនិត្យកូនស្រីរបស់ខ្លួន គឺលោកគ្រូពេទ្យមិនទាន់ផ្ដល់ឲ្យខ្លួនឡើយ។ ខ្លួនសំណូមពរដល់តុលាការធ្វើការផ្ដន្ទាទោសជនល្មើសទៅតាមច្បាប់ និងសុំទាមទារសំណងជម្ងឺចិត្ត និងកិត្តិយសសេចក្ដីថ្លៃថ្នូរចំនួន៤០.០០០.០០០ លានរៀល។

- តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] នីតា បានឆ្លើយថា: ចំពោះរឿងហេតុដែលកើតឡើងគឺ: នៅថ្ងៃខែមិនចាំ ឆ្នាំ២០២២ នៅពេលនោះ បងសំណាង បានបបួលខ្លួនចុយគ្នា ពេលនោះបងសំណាងបានឲ្យសួរគ្រាប់ ខ្លួនប្រាប់ទៅបងសំណាងថាម្ដាយខ្លួនមិនឲ្យធ្វើអញ្ចឹងទេ ហើយបងសំណាងសុំតែម្ដងទេ

[redacted]

បងសំណាងបានដឹកដៃខ្លួនឡើងទៅលើផ្ទះចូលកន្លែងគាត់ដេក ខ្លួនមិនបានស្រែកទេ ដោយសារខ្លាចម៉ាក់វ៉ៃ ហើយគាត់បានធ្វើសកម្មភាពយកពងរបស់គាត់មកដាក់ចូលទៅក្នុងកាដួយខ្លួន។ បន្ទាប់មក បងណាងបានប្រាប់ខ្លួនថា កុំឲ្យប្រាប់ម្ដាយ។

- មេធាវី [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនរងគ្រោះបានធ្វើសេចក្ដីសន្និដ្ឋានការពារថាៈ ជនជាប់ចោទបានទទួលស្គាល់ថា ពិតជាបានរួមភេទជាមួយជនរងគ្រោះឈ្មោះ[redacted]នីតា ពិតមែន ទោះបីមិនស៊ីជម្រៅក៏ធ្វើឲ្យប៉ះពាល់ដល់ជនរងគ្រោះហើយ។ ចំពោះសំណាងដែលដើមបណ្ដឹងទាមទារ ព្រោះធ្វើឲ្យប៉ះពាល់ដល់កេរ្តិ៍ឈ្មោះ កិត្តិយសដល់ក្មេងស្រីយ៉ាងធ្ងន់ធ្ងរ និងប៉ះពាល់ដល់កេរ្តិ៍ឈ្មោះ កិត្តិយសក្រុមគ្រួសាររបស់គាត់ផងដែរ និងប៉ះពាល់ដល់អារម្មណ៍របស់ក្មេងស្រីរងគ្រោះ។ សំណូមពរផ្ដន្ទាទោសតាមច្បាប់ និងពិចារណាទៅលើសំណង។

- តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានប្ដឹងសុំថាៈ ក្នុងអង្គសវនាការឃើញថា ជនជាប់ចោទបានសារភាពថាបានធ្វើទៅលើឈ្មោះ នីតា ប្រាកដមែន។ ដូច្នេះ តំណាងអយ្យការរក្សាការចោទប្រកាន់ដូចនៅក្នុងដីកាសន្និដ្ឋានស្ថាពរលេខ ១១៨២ ដក.សព ចុះថ្ងៃទី១១-១០-២០២២ ទុកជាបានការដដែល និងស្នើសុំឲ្យក្រុមប្រឹក្សាជំនុំជម្រះសម្រេចផ្ដន្ទាទោសជនជាប់ចោទតាមច្បាប់ ។

- មេធាវី [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទបានធ្វើសេចក្ដីសន្និដ្ឋានការពារថាៈ តាមអង្គហេតុឈ្មោះ សំណាង ជាអនីតិជន ស្នើសុំតុលាការពិចារណាទៅលើច្បាប់យុត្តិធម៌អនីតិជន។ វិធានការកន្លងមកឈ្មោះ សំណាង អត់ដែលធ្វើអ្វីខុសទេ ទៅរៀនត្រឹមត្រូវ អត់ដែលប្រើប្រាស់គ្រឿងញៀន មានឪពុកម្ដាយ និងការសម្រេចឃុំខ្លួនគាត់នេះមិនស្របតាមច្បាប់ស្ដីពីយុត្តិធម៌អនីតិជនទេ។ ឥឡូវនេះគាត់មានបញ្ហារមាស់ធ្ងន់ធ្ងរ ហើយការព្យាបាលនៅមន្ទីរឃុំឃាំងនេះ គឺមានថ្នាំតិចតួចបំផុត ហើយធ្វើឲ្យគាត់ខាតមិនបានរៀនសូត្រ គប្បីតុលាការពិចារណាសម្រាលទោសគាត់ឲ្យបានទាបបំផុត បើសិនបន្តឃុំខ្លួនគាត់ទៀតធ្វើឱ្យប៉ះពាល់ដល់អនាគតរបស់គាត់ ហើយគោលបំណងនៃការឃុំខ្លួនគឺអប់រំកែប្រែ ដើម្បីឲ្យគាត់អាចចូលក្នុងសង្គមវិញ។ ការបន្តឃុំខ្លួនក្នុងស្ថានភាពអញ្ចឹងដែលគាត់ជាអនីតិជនមិនមែនជាការល្អទេ ឆ្លងតាមស្មារតីនៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន។ សុំតុលាការផ្ដន្ទាទោសទៅលើជនជាប់ចោទឈ្មោះ [redacted]សំណាង ដោយអនុវត្តតាមគោលការណ៍ជាមូលដ្ឋានដែលអនុវត្តចំពោះអនីតិជន ដូចដែលមានចែងនៅក្នុងចំណុចទី១ និងទី៤ នៃមាត្រា ១០០ នៃក្រមព្រហ្មទណ្ឌ ដែលអនុវត្តចំពោះអនីតិជនដែលមានអាយុចាប់ពី ១៤ឆ្នាំឡើង និងអនុវត្តស្របតាមមាត្រា ១៦៤ ចំណុចទី២ ទី៣ ដែលនិយាយពីការទទួលប្រយោជន៍ការសម្រាលទោសរបស់អនីតិជន។ ស្នើសុំតុលាការសម្រេចអនុវត្តទោសព្យួរលើជនជាប់ចោទ។

- សំដីចុងក្រោយរបស់ជនជាប់ចោទៈ សុំបន្ធូរបន្ថយទោស ។

- ក្រោយពីបានស្ដាប់ចម្លើយរបស់ជនជាប់ចោទ

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ២០២៣
ក្រឡាបញ្ជី

[redacted]

Scanned with CamScanner

- ក្រោយពីបានស្ដាប់ចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី និងជនរងគ្រោះ
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានការពាររបស់មេធាវីជនរងគ្រោះ
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានការពាររបស់មេធាវីជនជាប់ចោទ
- ក្រោយពីបានស្ដាប់សំដីចុងក្រោយរបស់ជនជាប់ចោទ
- ក្រោយពីបានពិនិត្យភស្តុតាងនានា
- ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ខេត្តកណ្ដាល ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ២០២៣
ក្រឡាបញ្ជី
[redacted]

## សាលាដំបូងខេត្តកណ្ដាល
## យល់ឃើញថា

១-តាមចម្លើយរបស់ជនជាប់ចោទ, ជនរងគ្រោះ និងដើមបណ្ដឹងរដ្ឋប្បវេណី មានលក្ខណៈស៊ីសង្វាក់គ្នាទៅនឹងរបាយការណ៍លេខ ៤២០ របក ចុះថ្ងៃទី១៩-០៩-២០២២ របស់អធិការដ្ឋាននគរបាលស្រុកខ្សាច់កណ្ដាល ព្រមទាំងលិខិតគតិយុត្តនានារបស់មន្ត្រីនគរបាលយុត្តិធម៌ ដែលអាចបញ្ជាក់បានថា កាលពីថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២២ នៅវេលាម៉ោង ១១ ថ្ងៃត្រង់ ជនជាប់ចោទឈ្មោះ [redacted] សំណាង ភេទប្រុស អាយុ ១៥ឆ្នាំ បានធ្វើសកម្មភាពលួងជនរងគ្រោះឈ្មោះ [redacted] នីតា ភេទស្រី អាយុ ០៦ឆ្នាំ ឱ្យឡើងទៅលើផ្ទះ រួចជនជាប់ចោទក៏បានចាប់ស្រាតខោរបស់ក្មេងស្រីរងគ្រោះ ហើយក៏បានយកប្រដាប់ភេទរបស់ខ្លួន ដាក់ចូលទៅក្នុងប្រដាប់ភេទរបស់ជនរងគ្រោះឈ្មោះ [redacted] នីតា បានសម្រេចចេញទឹកកាម។ ឃើញថា អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] សំណាង គឺជាបទល្មើសរំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ មិនមែនជាបទល្មើស រួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ។ គប្បីប្ដូរការចោទប្រកាន់ពីបទ រួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ ទៅជាបទ រំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ ។

២-យោងតាមប័ណ្ណសុខភាពកុមារីរបស់ជនរងគ្រោះឈ្មោះ [redacted] នីតា ឃើញថា ជនរងគ្រោះឈ្មោះ [redacted] នីតា មានថ្ងៃខែឆ្នាំកំណើត ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៦ ដែលបញ្ជាក់បានថា ជនរងគ្រោះឈ្មោះ [redacted] នីតា គិតត្រឹមថ្ងៃកើតហេតុ ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២២ គឺជាអនីតិជនទើបតែមានអាយុ ០៦ឆ្នាំ ០១ខែ ១៧ថ្ងៃ ប៉ុណ្ណោះ មិនទាន់គ្រប់អាយុនៅក្នុងការរួមភេទនៅឡើយទេ។

៣-ថ្វីត្បិតតែសំណុំរឿងនេះ មិនមានឯកសារលិខិតកោសលវិច័យវេជ្ជសាស្ត្របញ្ជាក់អំពីអាការៈរបស់ជនរងគ្រោះឈ្មោះ [redacted] នីតា ក៏ពិតមែន ប៉ុន្តែតាមចម្លើយសារភាពរបស់ជនជាប់ចោទ និងតាមចម្លើយរបស់ជនរងគ្រោះបានឆ្លើយរៀបរាប់អំពីសកម្មភាពរបស់ជនជាប់ចោទឈ្មោះ [redacted] សំណាង ដែលបានធ្វើសកម្មភាពមកលើខ្លួន បញ្ជាក់ឲ្យឃើញថា ជនជាប់ចោទឈ្មោះ [redacted] សំណាង ពិតជាបានប្រព្រឹត្តអំពើ រំលោភ



Scanned with CamScanner

សេពសន្ថវៈមានស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ យ៉ាងពិតប្រាកដមែន។

៤-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] សំណាង ដែលបានធ្វើសកម្មភាព រំលោភសេពសន្ថវៈទៅលើជនរងគ្រោះឈ្មោះ [redacted] នីតា ដែលទើបតែមានអាយុ ០៦ឆ្នាំ ០១ខែ ១៧ថ្ងៃ ស្តែងឡើងដោយចេតនាទុច្ចរិត គឺជាអំពើធ្វើឲ្យប៉ះពាល់ដល់សណ្ដាប់ធ្នាប់ របៀបរៀបរយសាធារណៈ និងសន្តិសុខសង្គម ជាពិសេសធ្វើឲ្យប៉ះពាល់ដល់កិត្តិយស សេចក្ដីថ្លៃថ្នូររបស់ជនរងគ្រោះ និងក្រុមគ្រួសារជនរងគ្រោះ ហើយអំពើនោះទៀតជាអំពើផ្ទុយច្បាប់ និងកំណត់ថាជាបទល្មើស រំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ ដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៤១ នៃក្រមព្រហ្មទណ្ឌ។

៥-ជនជាប់ចោទឈ្មោះ [redacted] សំណាង គឺជាអនីតិជន មានស្មារតីដឹងខុសត្រូវនូវអំពើនិងព្យសនកម្ម ដែលកើតឡើងចេញពីអំពើប្រព្រឹត្តរបស់ខ្លួន ហើយមានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវតាមផ្លូវច្បាប់។

៦-ពុំមានភស្តុតាងជាឯកសារ ឬសេចក្ដីបញ្ជាក់ណាមួយពីសាក្សីជាអ្នកជំនាញផ្នែកវេជ្ជសាស្ត្រ ដែលបានបង្ហាញថា ជនជាប់ចោទឈ្មោះ [redacted] សំណាង ជាជនកើតវិបល្លាសស្មារតីដែលធ្វើឲ្យបាត់បង់នូវការយល់ដឹងខុសត្រូវរបស់ខ្លួន ដែលជាមូលហេតុនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌ ដូចមានបញ្ញត្តិក្នុងមាត្រា ៣១ នៃក្រមព្រហ្មទណ្ឌនោះទេ។

៧-គ្មានភស្តុតាងជាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] សំណាង ភេទប្រុស អាយុ១៥ឆ្នាំ ពីបទៈ រួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ ប្រព្រឹត្តនៅភូមិព្រែកថោង ឃុំព្រែកលួង ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល កាលពីថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២២។ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

៨-មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] សំណាង ភេទប្រុស អាយុ១៥ឆ្នាំ ពីបទៈ រំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ ប្រព្រឹត្តនៅភូមិព្រែកថោង ឃុំព្រែកលួង ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល កាលពីថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២២។ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៤១ នៃក្រមព្រហ្មទណ្ឌ។

៩-តាមការប្តឹងសុំរបស់តំណាងអយ្យការមកតុលាការឱ្យផ្តន្ទាទោសជនជាប់ចោទឈ្មោះ នៀ សំណាង ពីបទៈ រួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ តាមបញ្ញត្តិមាត្រា ៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។ តុលាការយល់ឃើញថាៈ ការប្តឹងសុំនេះមិនមានមូលដ្ឋានតាមផ្លូវច្បាប់គ្រប់គ្រាន់ឡើយ គប្បីតុលាការមិនសម្រេចតាមការប្តឹងសុំទេ។

១០-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចន្ថា ប្តឹងទាមទារសំណងជំងឺចិត្តជាប្រាក់ចំនួន ៤០.០០០.០០០០ (សែសិបលាន) រៀល គប្បីក្រុមប្រឹក្សាជំនុំជម្រះពិចារណា។

បានចំលងត្រឹមត្រូវតាមច្បាប់ដើម
ក្រឡាបញ្ជី

[redacted]



Scanned with CamScanner

# ហេតុដូច្នេះសម្រេច

១-ប្តូរការចោទប្រកាន់លើឈ្មោះ [redacted] សំណាង ភេទប្រុស អាយុ១៥ឆ្នាំ (កើតឆ្នាំ២០០៧) ពីបទៈ រួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ តាមបញ្ញត្តិមាត្រា៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ទៅជាបទៈ រំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ តាមបញ្ញត្តិមាត្រា ២៤១ នៃក្រមព្រហ្មទណ្ឌ។

២-ផ្តន្ទាទោសៈ ជនជាប់ចោទឈ្មោះ [redacted] សំណាង ភេទប្រុស អាយុ១៥ឆ្នាំ (កើតឆ្នាំ២០០៧) ជាអនីតិជន ដាក់ពន្ធនាគារកំណត់ចំនួន ០៣ (បី)ឆ្នាំ ០៦ (ប្រាំមួយ) ខែ ។

ពីបទៈ រំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ ប្រព្រឹត្តនៅភូមិព្រៃកថោង ឃុំព្រៃកលួង ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២២។ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៤១ និងមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ។

៣-បង្គាប់ឲ្យឈ្មោះ [redacted] សារ៉ុន (ឪពុក) និងឈ្មោះ [redacted] យឿន (ម្តាយ) ឬអាណាព្យាបាលរបស់ឈ្មោះ [redacted] សំណាង សងសំណងជំងឺចិត្តជាប្រាក់ចំនួន ១៥.០០០.០០០ (ដប់ប្រាំលាន) រៀល ទៅឈ្មោះ [redacted] ចន្ថា ជាដើមបណ្តឹងរដ្ឋប្បវេណី។ ការទាមទារលើសពីនេះត្រូវច្រានចោល។

៤-សាលក្រមនេះជំនុំជម្រះជាសាធារណៈ ចំពោះមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី។

- ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ -

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|---|
| ហត្ថលេខា និងត្រា: | ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា និងត្រា: |

[redacted]

"បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃអង្គារ ៩កើត ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

កណ្តាល, ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម [redacted]

ខេត្តកណ្តាល ថ្ងៃទី ២៨ ខែ ៣ ឆ្នាំ២០២៣

ក្រឡាបញ្ជី

[redacted]